# ព្រះរាជាណាចក្រកម្ពុជា

## ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា
លេខៈ..៣២....ស.សរ

## សេចក្តីសំរេច

### ស្តីពី

### ការបង្កើតគណៈកម្មាធិការជាតិ ដើម្បីទប់ស្កាត់ លុបបំបាត់ និងបង្ក្រាបការកាប់រាន ដុត ឈូសឆាយ និងហ៊ុមព័ទ្ធដីព្រៃឈើ ដើម្បីទាតយកដីធ្វើកម្មសិទ្ធិ នៅតាមបណ្តាខេត្ត-ក្រុងមួយចំនួន នៃព្រះរាជាណាចក្រកម្ពុជា

### រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/ រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៣ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងកសិកម្ម រុក្ខា ប្រមាញ់ និងនេសាទ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៨០២/០១៦ ចុះថ្ងៃទី ៣១ ខែ សីហា ឆ្នាំ ២០០២ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីព្រៃឈើ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៨០១/១៤ ចុះថ្ងៃទី ៣០ ខែ សីហា ឆ្នាំ ២០០១ ដែលប្រកាសឱ្យប្រើច្បាប់ភូមិបាល
- បានឃើញព្រះរាជក្រមលេខ នស/រកម/១២៩៦/៣៦ ចុះថ្ងៃទី ២៤ ខែ ធ្នូ ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីកិច្ចការពារបរិស្ថាន និងការគ្រប់គ្រងធនធានធម្មជាតិ
- យោងតាមតំរូវការចាំបាច់របស់រាជរដ្ឋាភិបាល

**ប្រការ១.-**

បង្កើតគណៈកម្មាធិការជាតិ ដើម្បីទប់ស្កាត់ លុបបំបាត់ និងបង្ក្រាបការកាប់រានដុត ឈូសឆាយ និងហ៊ុមព័ទ្ធដីព្រៃឈើ ដើម្បីវាតយកដីធ្វើកម្មសិទ្ធិ នៅតាមបណ្តាខេត្ត-ក្រុងមួយចំនួននៃព្រះរាជាណាចក្រកម្ពុជា ដែលមានសមាសភាពដូចខាងក្រោម ÷

| | | | |
|---|---|---|---|
| ១- ឯកឧត្តម | **ចាន់ សារុន** | រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខា ប្រមាញ់ និងនេសាទ | ប្រធាន |
| ២- ឯកឧត្តម | **ឯម សំអាន** | រដ្ឋលេខាធិការក្រសួងមហាផ្ទៃ | អនុប្រធាន |
| ៣- ឯកឧត្តម | **ម៉ុន អ៊ុយ** | អនុរដ្ឋលេខាធិការទីស្តីការគណៈរដ្ឋមន្ត្រី | សមាជិក |
| ៤- ឯកឧត្តម | **ម៉ុន សំ** | អនុរដ្ឋលេខាធិការក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ | សមាជិក |
| ៥- ឯកឧត្តម | **វង្ស សារិន** | អនុរដ្ឋលេខាធិការក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ | សមាជិក |
| ៦- ឯកឧត្តម | **ទឹក គ្រឿនឧត្តរា** | អនុរដ្ឋលេខាធិការក្រសួងបរិស្ថាន | សមាជិក |
| ៧- ឯកឧត្តម | **អ៊ុំ ជិន** | អនុរដ្ឋលេខាធិការក្រសួងយុត្តិធម៌ | សមាជិក |
| ៨-ឯកឧត្តមឧត្តមសេនីយ៍ឯក | **ខា នារា** | ក្រសួងការពារជាតិ និងអគ្គបញ្ជាការដ្ឋាននៃកងយោធពលខេមរភូមិន្ទ | សមាជិក |
| ៩- ឯកឧត្តមឧត្តមសេនីយ៍ទោ | **ម៉ាន់ ណាយ** | អគ្គស្នងការដ្ឋាននគរបាលជាតិ | សមាជិក |
| ១០- ឯកឧត្តម | **តិច ចំរួនតារា** | អគ្គនាយកគណៈកម្មាធិការសិទ្ធិមនុស្សកម្ពុជា | សមាជិក |
| ១១- លោកវរៈសេនីយ៍ឯក | **ទ្រាក់ សិទ្ធិ** | បញ្ជាការដ្ឋានកងរាជអាវុធហត្ថលើផ្ទៃប្រទេស | សមាជិក |
| ១២- ឯកឧត្តម | អភិបាលខេត្ត-ក្រុងសាមី | | សមាជិក |
| ១៣- ឯកឧត្តម | **ទី សុគន្ធ** | ប្រធានរដ្ឋបាលព្រៃឈើ | អគ្គលេខាធិការប្រតិបត្តិ |

**ប្រការ២.-**

គណៈកម្មាធិការជាតិនេះ មានតួនាទី និងភារកិច្ចដូចតទៅ ÷

១- រៀបចំ និងអនុវត្តផែនការសកម្មភាពផ្សព្វផ្សាយច្បាប់ លិខិតបទដ្ឋានដែលពាក់ព័ន្ធទៅនឹងដីព្រៃឈើគ្រប់ប្រភេទ ។

២- ត្រួតពិនិត្យ និងស្រាវជ្រាវដល់មូលដ្ឋានដែលមានការកាប់រានដីព្រៃខុសច្បាប់ ក្នុងគោលបំណងធ្វើជាកម្មសិទ្ធិផ្ទាល់ខ្លួន ឬទុកធ្វើអាជីវកម្មបន្ត ។

៣- ចាត់វិធានការទប់ស្កាត់ លុបបំបាត់ និងបង្ក្រាបឱ្យទាន់ពេលវេលា នូវរាល់ការកាប់រាន ដុត ឈូសឆាយ និងហ៊ុមព័ទ្ធកាន់កាប់ដីព្រៃឈើគ្រប់ប្រភេទ ។

៤- ធ្វើសហប្រតិបត្តិការជាមួយអង្គការអន្តរជាតិ និងសហគមន៍អ្នកផ្តល់ជំនួយ ដើម្បីជំរុញ និងគាំទ្រការងារនេះ ។

៥- ធ្វើរបាយការណ៍ និងលើកអនុសាសន៍ ជូនរាជរដ្ឋាភិបាលលើការអនុវត្តផែនការសកម្មភាព ។

៦- បង្កើតយន្តការអនុវត្តតាមខេត្ត-ក្រុងនីមួយៗតាមការចាំបាច់នូវអនុគណៈកម្មាធិការមួយ ដែលមានឯកឧត្តមអភិបាលខេត្ត-ក្រុងជាប្រធានដើម្បីបំពេញការងារអនុវត្តភារកិច្ចនានាដែលគណៈកម្មាធិការជាតិផ្តល់អោយ ។

**ប្រការ៣.-**

សមាជិកគណៈកម្មាធិការជាតិ ត្រូវចូលរួមទទួលខុសត្រូវក្នុងក្របខ័ណ្ឌសមត្ថកិច្ច ភារកិច្ចរបស់ខ្លួន និងត្រូវចូលរួមប្រជុំតាមការអញ្ជើញរបស់ប្រធាន ។

**ប្រការ៤.-**

គណៈកម្មាធិការជាតិនេះ មានអគ្គលេខាធិការដ្ឋានប្រតិបត្តិនៅរដ្ឋបាលព្រៃឈើ ដែលមានសិទ្ធិប្រើប្រាស់ត្រារបស់ក្រសួងកសិកម្ម រុក្ខា ប្រមាញ់ និងនេសាទ ដើម្បីអនុវត្តភារកិច្ច និងសំរួលការងាររបស់ខ្លួន ។

**ប្រការ៥.-**

រាល់ការចំណាយរបស់អគ្គលេខាធិការដ្ឋាន ជាបន្ទុករបស់ក្រសួងកសិកម្ម រុក្ខា ប្រមាញ់ និងនេសាទ ។

**ប្រការ៦.-**

គណៈកម្មាធិការជាតិ មានសិទ្ធិចាត់តាំងក្រុមការងារផ្សេងទៀតតាមការចាំបាច់ ។

**ប្រការ៧.-**

អនុគណៈកម្មការដែលជាយន្តការអនុវត្តមានសិទ្ធិប្រើប្រាស់ត្រារបស់អភិបាលខេត្ត-ក្រុងពាក់ព័ន្ធ ។

**ប្រការ៨.-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងការពារជាតិ រដ្ឋមន្ត្រីក្រសួងបរិស្ថាន រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគររូបនីយកម្ម និងសំណង់ រដ្ឋមន្ត្រីក្រសួងយុត្តិធម៌ អគ្គមេបញ្ជាការកងយោធពលខេមរភូមិន្ទ អគ្គស្នងការនគរបាលជាតិ មេបញ្ជាការកងរាជអាវុធហត្ថលើផ្ទៃប្រទេស អភិបាលខេត្ត-ក្រុងពាក់ព័ន្ធ និងសាមីជនដូចមានចែងក្នុងប្រការ ១ នៃសេចក្តីសំរេចនេះ ត្រូវអនុវត្តសេចក្តីសំរេចនេះ ចាប់ពីថ្ងៃចុះហត្ថលេខា តទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី ០១ ខែ មិថុនា ឆ្នាំ ២០០៤

**នាយករដ្ឋមន្ត្រី**

**ហ៊ុន សែន**

**កន្លែងទទួល**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យឯកឧត្តមឧបនាយករដ្ឋមន្ត្រី
- ដូចប្រការ៨
- ឯកសារ-កាលប្បវត្តិ